


ដូចសាធារណជនបានជ្រាបហើយថាក្នុងរយៈពេលជាច្រើនខែមកនេះ **បាតុភូតអែលនីណូ** បាននិងកំពុងជះឥទ្ធិពល (ក្តៅនិងស្ងួតខ្លាំង) មកលើតំបន់អាស៊ី ជាពិសេសលើតំបន់អាស៊ីអាគ្នេយ៍ ក្នុងនោះមានកម្ពុជាផងដែរ។ ឥទ្ធិពលនេះបានបង្កឲ្យកម្ពស់ទឹកទន្លេមានកម្រិតទាបខ្លាំង ហើយនិងការឡើងកម្តៅ និងភាពរាំងស្ងួតអូសបន្លាយមិនធ្លាប់ជួបប្រទះជាច្រើនទសវត្សមកនេះ។ ពាក់ព័ន្ធនឹងផលប៉ះពាល់នេះ កន្លងមក រាជរដ្ឋាភិបាលកម្ពុជា បានអំពាវនាវដល់ប្រជាកសិករ ឲ្យធ្វើស្រែប្រាំងតែម្តងនិងប្រជាពលរដ្ឋសន្សំសំចៃទឹកទុកប្រើប្រាស់ប្រចាំថ្ងៃ ហើយក៏បានណែនាំ ដល់សមត្ថកិច្ចពាក់ព័ន្ធត្រៀមនិងជួយអន្តរាគមន៍ដល់ប្រជាពលរដ្ឋផងដែរ។

ដោយឡែកឆ្លើយតបចំពោះករណីនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបាននិងកំពុងចាត់វិធានការអន្តរាគមន៍ជួយដល់កសិករជាអាទិ៍ដូចខាងក្រោម៖

១) បាននិងកំពុងត្រៀមក្នុងដៃនូវ៖ គ្រាប់ពូជស្រូវ បន្លែ បសុឱសថ វ៉ាក់សាំងសត្វ ជាដើម ដើម្បីជួយអន្តរាគមន៍ដល់កសិករតាមការចាំបាច់

២) បានធ្វើការស្រាវជ្រាវបង្កើតពូជស្រូវ និងពូជបន្លែដែលធន់នឹងការប្រែប្រួលអាកាសធាតុ និងស្របទៅនឹងតម្រូវការផង ហើយក៏បានកំពុងធ្វើការផ្សព្វផ្សាយជូនដល់កសិករគ្រប់ភូមិ ឃុំ ស្រុក។

៣) ឯកឧត្តមរដ្ឋមន្ត្រីបានធ្វើការណែនាំឱ្យមន្ទីរកសិកម្ម រៀបចំ និងលើកគម្រោងជីកប្រឡាយតពីប្រឡាយមេទៅកាន់ស្រែ និងកសិដ្ឋានរបស់ប្រជាកសិករ។

៤) បាន និងកំពុងធ្វើសហប្រតិបត្តិការជាមួយអង្គការជាតិនិងអន្តរជាតិជា ដៃគូ ហើយ និងដៃគូអភិវឌ្ឍន៍ ជាអាទិ៍៖ អង្គការស្បៀងនិងកសិកម្ម នៃសហប្រជាជាតិ (FAO), មូលនិធិអន្តរជាតិអភិវឌ្ឍន៍កសិកម្ម (IFAD) សហភាពអឺរុប(EU)… ជួយដល់ប្រជាកសិករ។